00416912

C22/9/2

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**<u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ ៣២) |
| ដាក់ទៅ | : | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់ | : | ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 17 / 12 / 2009
ម៉ោង (Time/Heure) : 11:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: C.A.Try

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ / Public / Redacted Version

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ស្ដីពីការបន្តថិរវេលានៃការឃុំខ្លួន**

---

**<u>អ្នកដាក់ឯកសារ:</u>**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH
លោក សេង ប៊ុនឃាង
លោក Anees AHMED

**<u>អ្នកទទួលឯកសារ:</u>**
**អង្គបុរេជំនុំជម្រះ:**
ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING, QC
ចៅក្រម ន៉ី ធុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី:**
លោក គឹម ម៉េងឃី
កញ្ញា ម៉ុច សុវណ្ណារី
លោកស្រី Martine JACQUIN
លោក Philippe CANONNE
លោកស្រី Elizabeth RABESANDRATANA
លោកស្រី Annie DELAHAIE
លោកស្រី Fabienne TRUSSES-NAPROUS
លោក នី ចាន់ឌី
លោក ឡោ ជុនធី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 18 / 12 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ក្រុមមេធាវី អៀង សារី**
លោក អាង ឧត្តម
លោក MichaelG.KARNAVAS

កញ្ញា SILKE Studzinsky
លោក គង់ ពិសី
លោក ហុង គឹមសួន
លោក យុង ផានិត
លោកស្រី ស៊ីន សុវ៉ន
លោក Mahdev MOHAN
លោកស្រី NGUYEN Lyma
កញ្ញា Marie GUIRAUD
លោក Patrick BAUDOUIN
លោក Olivier BAHOUGNE
លោក David BLACKMAN

## ១. សេចក្តីផ្តើម

១. ជនត្រូវចោទ អៀង សារី បានដាក់បណ្តឹងឧទ្ធរណ៍មួយ ("បណ្តឹងឧទ្ធរណ៍")[1] ដោយស្វែងរកឱ្យមានការផ្លាស់ប្តូរនូវដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ("ដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនលើកទីពីរ") ដែលបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើរូបគាត់ សម្រាប់រយៈពេលបន្ថែមទៀតមិនលើសពីមួយឆ្នាំ[2] ។ គាត់អះអាងថា (១) សិទ្ធិរបស់គាត់ក្នុងការទទួលបានសេរីភាព និងសច្ចធារណ៍នៃនិរទោស ត្រូវបានរំលោភ តាមរយៈការបន្តចិរវេលានៃការឃុំខ្លួនដូច្នេះ ដោយហេតុថាលក្ខខណ្ឌដែលតម្រូវឱ្យមានសម្រាប់ការឃុំខ្លួនគាត់ ដូចចែងក្នុងវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង មិនត្រូវបានបំពេញឡើយ[3], (២) សហចៅក្រមស៊ើបអង្កេត បានរំលោភលើឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការខកខានមិនបានពិចារណាលើវិធានការផ្សេងពីនេះ ដែលមានលក្ខណៈស្រាលជាងការឃុំខ្លួន ដែលអាចយកមកប្រើដើម្បីធានាថា ដើមបណ្តឹងឧទ្ធរណ៍នឹងមានវត្តមាននៅពេលកាត់សេចក្តីដោយមិនមានហានិភ័យដល់សន្តិសុខផ្ទាល់ខ្លួនរបស់គាត់ ឬការរំខានដល់សណ្តាប់ធ្នាប់សាធារណៈដែរ[4] ។

២. សហព្រះរាជអាជ្ញា ស្នើឱ្យអង្គបុរេជំនុំជម្រះ ច្រានចោលបណ្តឹងឧទ្ធរណ៍នេះ ដោយសារមូលហេតុខាងក្រោមនេះ *នៅក្នុងចំណោមទឡ្ហីករណ៍ផ្សេងៗទៀត* ៖

(ក) ដើមបណ្តឹងឧទ្ធរណ៍ ខកខានមិនបានបង្ហាញឱ្យឃើញអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយ តាំងពីដើមដំបូងនៃការឃុំខ្លួនរូបគាត់ដោយសហចៅក្រមស៊ើបអង្កេត នៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ("ដីកាសម្រេចឃុំខ្លួនដើម")[5]។ ជាពិសេសគាត់មិនបានបង្ហាញអំពីការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងណាមួយ តាំងពីមានការបញ្ជាក់អះអាងអំពីការឃុំខ្លួនបណ្តោះអាសន្នលើរូបគាត់ ដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨ មកម្ល៉េះ ("សាលដីកាលើបណ្តឹង

---

[1] *ករណីរបស់ អៀង សារី,* បណ្តឹងឧទ្ធរណ៍ អៀង សារី ប្រឆាំងនឹងដីកាសម្រេចបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០០៩, ឯកសារលេខ C22/9/1, ERN 00411501-00411512 [*ចាប់ពីនេះតទៅហៅថា* បណ្តឹងឧទ្ធរណ៍] ។

[2] *ករណីរបស់ អៀង សារី,* ដីកាសម្រេចអំពីការបន្តចិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ឯកសារលេខ C22/8, ERN 00399377-00399388 ។

[3] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១ ។

[4] ក្នុងឯកសារដដែលដូចខាងលើ ។

[5] *ករណីរបស់ អៀង សារី,* ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧, ឯកសារលេខ C22, [*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចឃុំខ្លួនលើកទីមួយ] ។

ឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនដើម")[6], តាំងពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើកទីមួយ ចុះថ្ងៃទី១១ ខែ ធ្នូ ឆ្នាំ២០០៨ ("ដីកាសម្រេចបន្តឃុំខ្លួនលើកទីមួយ")[7] ឬក៏ការតម្កល់ដីកាសម្រេចនោះដោយអង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ("សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ")[8] ។ នៅក្នុង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនដើម ដែលបានវាយតម្លៃលើភស្តុតាងទាំងអស់នៅលើសំណុំរឿងដែលមានបច្ចុប្បន្នភាពដល់ពេលសវនាការ អង្គបុរេជំនុំជម្រះបានកត់សំគាល់ឃើញថា លក្ខខណ្ឌតម្រូវនៃវិធាន ៦៣.៣.ក និង ៦៣.៣.ខ.៣-៥ ត្រូវបានបំពេញ ហើយ "ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាវិធានការចាំបាច់ ដោយឈរលើទឡ្ហីករណ៍ [ទាំងនោះ]"[9] ។ នៅក្នុង សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ អង្គបុរេជំនុំជម្រះបានកត់សំគាល់ឃើញថា [នៅពេលមានអត្ថិភាពនៃ "មូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់" រួចហើយ] លក្ខខណ្ឌនៃវិធាន ៦៣.៣.ក នៅក្នុងដំណាក់កាលនៃដំណើរការនីតិវិធីមុនពេលជំនុំជម្រះ នៅតែត្រូវបានបំពេញ វៀរលែងតែមានភស្តុតាងដោះបន្ទុកត្រូវបានរកឃើញផ្សេងពីនេះទៅវិញ"[10] ។

(ខ) សព្វថ្ងៃ សំណុំរឿងមានផ្ទុកនូវភស្តុតាងដែលមានលទ្ធភាពបំពេញបាន សម្រាប់អ្នកសង្កេតការណ៍ឯករាជ្យនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរនេះ ដែលថា ដើមបណ្តឹងឧទ្ធរណ៍អាចបានប្រព្រឹត្តឧក្រិដ្ឋកម្មនានាដែលគាត់បាន និងកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ ។ ពុំមានភស្តុតាងដោះបន្ទុកជាក់ស្តែងត្រូវបានរកឃើញដើម្បីរំលាយចោលនូវភស្តុតាងនេះទេ ។

---

[6] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនជនត្រូវចោទ អៀង សារី បណ្តោះអាសន្ន, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, ឯកសារលេខ C22/I/73, ERN 00232830-00232861 [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនដើម] ។

[7] *ករណីរបស់ អៀង សារី,* ដីកាសម្រេចអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨, ឯកសារលេខ C22/4, ERN 00238566-00238576 [*ចាប់ពីនេះតទៅហៅថា* ដីកាសម្រេចបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ] ។

[8] *ករណីរបស់ អៀង សារី,* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការបន្តថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន, ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩, ឯកសារលេខ C22/5/38, ERN 00343866-00343879 [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ] ។

[9] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនដើម, ការសម្រេចបញ្ចប់ ។

[10] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ, កថាខណ្ឌទី២១ ។

00416916



(គ) "កំហុសនៅក្នុងកិច្ចស៊ើបសួរ" ដែលមេធាវីការពារក្ដីបានតវ៉ា[11] ថាជាឧបសគ្គដល់ការវាយតម្លៃអំពីអត្ថិភាពនៃមូលហេតុនៃការឃុំខ្លួន គឺគ្រាន់តែជាភស្តុតាងដែលបានអះអាងដោយមេធាវីការពារក្ដីដែលតវ៉ាចំព្រោះប្រតិបត្តិការនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") តែប៉ុណ្ណោះ ដែលក្នុងចំណោមភស្តុតាងទាំងនេះ គ្មានភស្តុតាងណាមួយត្រូវបានអង្គបុរេជំនុំជម្រះ រកឃើញថាមានសុពលភាពឡើយ ។

(ឃ) ជាការបន្ថែម លក្ខខណ្ឌបី ក្នុងចំណោមលក្ខខណ្ឌដាច់ៗពីគ្នាទាំងប្រាំ ដែលមានចែងនៅក្នុងវិធាន ៦៣.៣.ខ នៃវិធានផ្ទៃក្នុង នៅតែបានបំពេញ។ អាស្រ័យហេតុនេះ ការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នជាវិធានការចាំបាច់មួយ ។ ជាពិសេស ការឃុំខ្លួនបណ្ដោះអាសន្នលើដើមបណ្ដឹងឧទ្ធរណ៍គឺជាការចាំបាច់ (ទី១) ដើម្បីធានាវត្តមានរបស់គាត់ក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធី, (ទី២) ដើម្បីការពារសន្តិសុខរបស់គាត់ និង/ឬ (ទី៣) ដើម្បីថែរក្សាសណ្ដាប់ធ្នាប់សាធារណៈ ។

(ង) អង្គបុរេជំនុំជម្រះសាលាដំបូងបានសង្កេតឃើញថា ការឃុំខ្លួនក្នុងផ្ទះ ឬសូម្បីតែឃុំខ្លួននៅមន្ទីរពេទ្យក៏ដោយ សម្រាប់ដើមបណ្ដឹងឧទ្ធរណ៍រូបនេះ គឺមិនត្រូវបានអនុញ្ញាតឡើយ ដោយសារមិនមានការផ្លាស់ប្ដូរកាលៈទេសៈជាក់ស្ដែងណាមួយ ដើម្បីយកធ្វើជាអង្គសេចក្ដីសម្រាប់ធ្វើការផ្លាស់ប្ដូរការសម្រេចនេះបាន ។ មន្ទីរឃុំឃាំង អ.វ.ត.ក នៅតែជាកន្លែងដែលមានការបំពាក់សម្ភារៈឧបករណ៍ដ៏សមស្របសម្រាប់ឃុំខ្លួនគាត់ ។

## ២. ច្បាប់

### *លក្ខខណ្ឌចាំបាច់សម្រាប់ការឃុំខ្លួន*

៣. តាមវិធាន ៦៣.៣ សហចៅក្រមស៊ើបអង្កេត អាចសម្រេចឃុំខ្លួនបណ្ដោះអាសន្នបាន ប្រសិនបើ៖

(ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជនត្រូវចោទអាចបានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលបានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ; និង

[11] បណ្ដឹងឧទ្ធរណ៍, កថាខ័ណ្ឌទី១៤ ។

(ខ) សហចៅក្រមស៊ើបអង្កេត ពិចារណាថា ការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ ដើម្បី៖

(១) រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ រារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និង អ្នកសមគំនិត ។

(២) ថែរក្សាភស្តុតាង ឬ ការពារមិនឱ្យបំផ្លាញភស្តុតាង ។

(៣) ធានាអំពីវត្តមានរបស់ជនត្រូវចោទ នៅក្នុងដំណើរការនីតិវិធី ។

(៤) ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

(៥) រក្សាសណ្តាប់ធ្នាប់សាធារណៈ ។

៤. ទឡ្ហីករណ៍ទាំងប្រាំដែលមានចែងនៅក្នុងវិធាន ៦៣.៣.ខ នៃវិធានផ្ទៃក្នុង គឺដាច់ៗគ្នា[12] ។ ពុំមានលក្ខខណ្ឌតម្រូវណាមួយដែលថា សហចៅក្រមស៊ើបអង្កេតត្រូវតែរកឱ្យឃើញថា គ្រប់ទឡ្ហីករណ៍ទាំងអស់ត្រូវតែបានបំពេញមុននឹងពិចារណាអំពីការឃុំខ្លួនបណ្តោះអាសន្នដែលជាវិធានការចាំបាច់ ឬថា ការបន្តថិរវេលានៃការឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានអនុញ្ញាត នោះទេ ។ ផ្ទុយមកវិញ ប្រសិនបើសហចៅក្រមស៊ើបអង្កេតពិចារណាថា មានទឡ្ហីករណ៍មួយ ក្នុងចំណោមទឡ្ហីករណ៍ទាំងប្រាំ នោះការសាកល្បងសម្រាប់ការឃុំខ្លួន គឺត្រូវបានបំពេញហើយ ។ អភិក្រមនេះត្រូវបានអនុវត្តដោយបណ្តាសាលាក្តីព្រហ្មទណ្ឌដទៃទៀត ដែលធ្វើការដោះស្រាយចំពោះឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរស្រដៀងគ្នា[13] ។

---

[12] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនដើម, កថាខណ្ឌទី១២១ ។

[13] *រដ្ឋអាជ្ញា ទល់នឹង Sainovic និង Odjanic,* សាលដីកាច្រានចោលការអនុញ្ញាតការប្តឹងឧទ្ធរណ៍របស់ Odjanic, សំណុំរឿងលេខ: IT-99-37-AR65.2, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY, ចុះថ្ងៃទី២៧ មិថុនា ២០០៣, ទំព័រទី៣ ដែលបានអនុម័តយកតាមដោយអង្គបុរេជំនុំជម្រះ អ.វ.ត.ក នៅក្នុង*ករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច,* "សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ កាំង ហ្គេកអ៊ាវ ហៅ "ឌុច", សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អវតក/កសចស (អបជ ០១), ចុះថ្ងៃទី០៣ ធ្នូ ២០០៧, ERN 00154284-00154302, ឯកសារលេខ C5/45, កថាខណ្ឌទី៥៩ [*ចាប់ពីនេះតទៅហៅថា* សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួន ឌុច] ។

## *ការអនុវត្តន៍ឆន្ទានុសិទ្ធក្នុងការពិចារណាលើការឃុំខ្លួន*

៥. អាជ្ញាធរមួយរបស់តុលាការអាចអនុវត្តឆន្ទានុសិទ្ធក្នុងការកំណត់ថាតើ ការឃុំខ្លួនគឺជាវិធានការណ៍មួយដ៏ចាំបាច់ដែរឬទេ ឬមួយក៏ការបន្តថិរវេលានៃការឃុំខ្លួនត្រូវបានអនុញ្ញាត។ ឆន្ទានុសិទ្ធិបែបនេះតាមធម្មតាគឺត្រូវបានអនុវត្តដោយយកចិត្តទុកដាក់ ទៅលើរាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿង និងទៅលើរាល់អង្គហេតុដែលពាក់ព័ន្ធទាំងអស់នៃករណីរឿង ដែលក្នុងនោះរាប់បញ្ចូលទាំងស្ថានទម្ងន់នៃបទចោទប្រកាន់, ភាពសមហេតុសមផលនៃភស្តុតាង, អត្តចរិតនិងអាកប្បកិរិយាកន្លងមក និងបច្ចុប្បន្នរបស់ចុងចោទ, ផលប្រយោជន៍របស់សាក្សីនិងជនរងគ្រោះនានា, និងផលប្រយោជន៍នៃយុត្តិធម៌ទាំងមូលផង[14] ។ នេះគឺជាការស្របទៅតាមទម្លាប់អនុវត្តន៍នៅក្នុងតុលាការអន្តរជាតិនានា ដែលតុលាការនេះបានអនុម័តយកតាម[15] ។

## *ការបន្តថិរវេលានៃការឃុំខ្លួន*

៦. វិធាន៦៣.៦ នៃវិធានផ្ទៃក្នុង ចែងអំពីការពិនិត្យជាថ្មីឡើងវិញជាស្វ័យប្រវត្តិមួយតាមកាលកំណត់អំពីការឃុំខ្លួនរបស់ជនត្រូវចោទ ។ បញ្ញត្តិបែបនេះគឺមិនឃើញមាននៅក្នុងឯកសារជាមូលដ្ឋានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវី (“ICTY”) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (“ICTR”) និងតុលាការពិសេសសម្រាប់ ប្រទេសសៀរ៉ាឡេអូន (“SCSL”) នោះទេ ។ ក៏ប៉ុន្តែតុលាការទាំងនោះតម្រូវថា ដើម្បីឲ្យការធ្វើពាក្យសារជាថ្មីឡើងវិញក្នុងការសុំដោះលែងបានទទួលជោគជ័យនោះ ចុងចោទត្រូវតែបង្ហាញឲ្យឃើញអំពី “មានការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែង”[16] ។

---

[14] *ករណីរឿងក្តីរបស់សហព្រះរាជអាជ្ញា ទល់នឹង Ljube Boskoski និង Johan Tarculovski,* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍អំពីបញ្ហាបន្ទាន់បន្ទំរបស់ Johan Tarculovski លើការឃុំខ្លួនបណ្តោះអាសន្ន, សំណុំរឿងលេខ IT-04-82-AR65.4, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ITCY, ចុះថ្ងៃទី២៧ កក្កដា ២០០៧, កថាខណ្ឌទី៤។

[15] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនរបស់ **ឌុច**, កថាខណ្ឌទី២៧។

[16] *ករណីរឿងក្តីរបស់សហព្រះរាជអាជ្ញា ទល់នឹង Ljube Boskoski និង Johan Tarculovski,* សេចក្តីសម្រេចស្តីពីការដាក់ញត្តិស្នើសុំជាថ្មីដើម្បីសុំឲ្យដោះលែងជាបណ្តោះអាសន្នរបស់ Johan Tarculovski, សំណុំរឿងលេខ IT-04-82-PT, អង្គជំនុំជម្រះសាលាសាលាដំបូង នៃតុលាការ ITCY, ចុះថ្ងៃទី១៧ មករា ២០០៧, កថាខណ្ឌទី៩។

00416919



៧. ក៏ប៉ុន្តែ ស្រដៀងគ្នានឹងវិធានរបស់តុលាការនេះ វិធាន១១៨ នៃវិធានស្តីពីនីតិវិធី នឹងភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ("ICC") តម្រូវឱ្យ អង្គបុរេជំនុំជម្រះ ត្រូវតែធ្វើការធ្វើការពិនិត្យសារថ្មីឡើងវិញរបស់ខ្លួនលើការឃុំខ្លួនបណ្តោះអាសន្នរបស់ជនត្រូវចោទ ឱ្យបានយ៉ាងហោចណាស់ក៏នៅរៀងរាល់ ១២០ថ្ងៃម្តងដែរ ។ អង្គបុរេជំនុំជម្រះរបស់តុលាការ ICC មាន "កាតព្វកិច្ចឯករាជ្យ និងខុសពីគេមួយ [...] ក្នុងការធានាឱ្យប្រាកដថា មិនមានជនណាម្នាក់ត្រូវបានគេឃុំខ្លួនមុនពេលក្នុងរយៈពេលមួយដែលមិនសមហេតុសមផលនោះទេ"[17] ។ អង្គបុរេជំនុំជម្រះ អាចធ្វើ ការកែប្រែសេចក្តីសម្រេចរបស់ខ្លួនស្តីពីការឃុំខ្លួនបាន "បើសិនជាមានការបង្ហាញគ្រប់គ្រាន់តាមលក្ខខណ្ឌថាការផ្លាស់ប្តូរខាងកាលៈទេសៈតម្រូវឱ្យធ្វើដូច្នេះ"[18] ។ នៅនៅឯតុលាការ ICC "អយ្យការគឺជាអ្នកត្រូវមានបន្ទុកក្នុងការបង្ហាញភស្តុតាងទាក់ទងទៅនឹងអត្ថិភាពដែលមានជាបន្តទៅទៀតនៃលក្ខខណ្ឌ [...] ស្តីពីការឃុំខ្លួនមុនពេលសវនាការ"[19] ។

៨. នៅតុលាការនេះ វិធានមិនបានតម្រូវឱ្យសហចៅក្រមស៊ើបអង្កេត ត្រូវស្តាប់សហព្រះរាជអាជ្ញា ឬភាគីណាមួយផ្សេងទៀតទេ លើកលែងតែតែជនត្រូវចោទ នៅពេលធ្វើការកំណត់អំពីការបន្តថិរវេលានៃការឃុំខ្លួន[20] ។ អត្ថិភាពនៃការពិនិត្យសារឡើងវិញជាថ្មីតាមកាលកំណត់ជាស្វ័យប្រវត្តិអំពីការឃុំខ្លួនគឺជាការផ្តល់ដល់ជនជាប់ឃុំនូវឱកាសដើម្បីឱ្យលើឡើងពីជំហររបស់ខ្លួន និងបើសិនជាត្រូវបានអនុញ្ញាត ក្នុងការអនុវត្តន៍នូវសិទ្ធក្នុងការប្តឹងឧទ្ធរណ៍របស់ខ្លួន[21] ។

## ៣. អង្គហេតុ និងសំអាង

---

[17] *សភាពការណ៍នៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងករណីរឿងរបស់ សហព្រះរាជអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui*, សេចក្តីសម្រេចស្តីពីការសង្កេតទៅលើការពិនិត្យឡើងវិញអំពីការឃុំខ្លួនបណ្តោះអាសន្នរបស់ Germaine Katanga, សំណុំរឿងលេខ ICC-01/04-01/07, អង្គជំនុំជម្រះសាលាសាលាដំបូង នៃតុលាការ ICC, ចុះថ្ងៃទី៩ កក្កដា ២០០៨, ទំព័រ៤ [*ដែលតទៅទៀតនៅក្នុងនេះហៅថា* សេចក្តីសម្រេចលើករណី Katanga ថ្ងៃទី៩ កក្កដា ២០០៨]។

[18] *សភាពការណ៍នៅសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ, នៅក្នុងករណីរឿងរបស់ សហព្រះរាជអាជ្ញា ទល់នឹង Germaine Katanga និង Mathieu Ngudjolo Chui*, ការពិនិត្យមើលឡើងវិញលើសេចក្តីសម្រេច ស្តីពីលក្ខខណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្នរបស់ Germaine Katanga, សំណុំរឿងលេខ ICC-01/04-01/07, អង្គជំនុំជម្រះសាលាសាលាដំបូង នៃតុលាការ ICC, ចុះថ្ងៃទី១៨ សីហា ២០០៨, ទំព័រ៦ ។

[19] សេចក្តីសម្រេចលើករណី Katanga ថ្ងៃទី៩ កក្កដា ២០០៨, ទំព័រ៤។

[20] វិធាន ៦៣.៧ នៃវិធានផ្ទៃក្នុង ។

[21] ដូចខាងលើ។

## ក. បណ្តឹងឧទ្ធរណ៍មិនបានបង្ហាញអត្តសញ្ញាណអំពីមានការផ្លាស់ប្តូរ កាលៈទេសៈជាក់ស្តែងនោះឡើយ

៩. ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញអត្តសញ្ញាណអំពីមានការផ្លាស់ប្តូរកាលៈទេសៈជាក់ស្តែងដែលចាំបាច់តម្រូវឲ្យធ្វើការពិនិត្យពិចារណាឡើងវិញទៅលើការឃុំខ្លួនរបស់ខ្លួននោះឡើយ ឬសូម្បីតែមានការផ្លាស់ប្តូរណាមួយនៅក្នុងលក្ខខណ្ឌនៃការឃុំខ្លួននោះក្តីក៏មិនមានបង្ហាញអត្តសញ្ញាណដែរ។ កាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ អង្គបុរេជំនុំជម្រះបានចេញសេចក្តីសម្រេចដោយមានសំអាងហេតុជាលើកទី២មួយ ដែលរក្សាទុកដដែលនូវភាពចាំបាច់ក្នុងការឃុំខ្លួនគាត់មុនពេលសវនាការ។

១០. ដើមបណ្តឹងឧទ្ធរណ៍តវ៉ាថា កំហុសនៅក្នុងការស៊ើបសួររបស់ កសចស គឺមានដូចជា ការមិនអាចមានលទ្ធភាពក្នុងការកំណត់ពីក្នុងសំណុំរឿងថា តើ “មូលហេតុដែលធ្វើឲ្យជឿជាក់យ៉ាងច្បាស់” មានអត្ថិភាពដែរឬទេ? ។ ដើមបណ្តឹងឧទ្ធរណ៍គាំទ្រដល់ការតវ៉ានេះ ដោយលើកយោងទៅលើញត្តិស្នើសុំនានាដែលគាត់បានដាក់នៅចំពោះមុខ អង្គបុរេជំនុំជម្រះ ប្រឆាំងនឹង កសចស ។ ដើមបណ្តឹងឧទ្ធរណ៍មិនបានបង្ហាញឲ្យឃើញថា តើសារណានានារបស់ខ្លួនស្តីពីប្រតិបត្តិការការងាររបស់ កសចស និងលទ្ធផលដែលមិនបានទទួលជោគជ័យរបស់ខ្លួនមកទល់ពេលនេះ អាចមានភាពគ្រប់គ្រាន់សម្រាប់បង្ហាញអំពី “កំហុស” ណាមួយនោះឡើយ ។ ដើមបណ្តឹងឧទ្ធរណ៍ក៏មិនបានបង្ហាញឲ្យឃើញទៀតថា តើការចោទប្រកាន់អំពីការមានកំហុសនៅក្នុងការស៊ើបសួរបែបនេះមុខជានឹងរារាំងដល់ការវាយតម្លៃអំពីភាពចាំបាច់នៃការឃុំខ្លួនរបៀបណានោះដែរ ។ ដើមបណ្តឹងឧទ្ធរណ៍បានលើកឡើងថា “ក្នុងសំណុំរឿងខ្វះខាតមិនមានភស្តុតាងដោះបន្ទុកគ្រប់គ្រាន់នោះ គឺទំនងជាដោយសារមានបញ្ហាជាច្រើនជាមួយនឹងកិច្ចស៊ើបសួរនោះហើយ” ប៉ុន្តែមិនបានបញ្ជាក់ថាតើបាត់មិនឃើញមានឯកសារដោះបន្ទុកអ្វីខ្លះនៅក្នុងសំណុំរឿង ឬថា តើភស្តុតាងណាខ្លះដែល កសចស អាចមិនបានចាប់អារម្មណ៍ដល់នោះឡើយ។ នីតិវិធីនៅក្នុងវិធាន-ដែលរាប់បញ្ចូលទាំងនីតិវិធីមោឃភាពផង - ដែលអនុញ្ញាតឲ្យដើមបណ្តឹងឧទ្ធរណ៍តវ៉ាចំពោះនីតិវិធីរបស់ កសចស នៅចំពោះមុខអង្គបុរេជំនុំជម្រះបាននោះ គឺជាវេទិការដ៏សមស្របសម្រាប់ការចោទប្រកាន់អំពីការ មានកំហុសនៅក្នុងកិច្ចស៊ើបសួរ ។ មកទល់ពេលនេះ ដើមបណ្តឹងឧទ្ធរណ៍មិនបានសម្រេចជោគជ័យនៅក្នុងការព្យាយាមប្តឹងតវ៉ារបស់ខ្លួនអំពីភាពដែលគួរឲ្យទុកចិត្តបាននៃកិច្ចស៊ើបសួររបស់ កសចស នៅចំពោះមុខអង្គបុរេជំនុំជម្រះនោះទេ ។ ការពិនិត្យជាថ្មីឡើងវិញចំពោះការចោទប្រកាន់ទាំងនេះនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃឃុំខ្លួន គឺវាមិនមែនជាការសមស្របឡើយ ។

ព្រោះដោយសារមូលហេតុទាំងនេះហើយបានជា សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលនូវមូលហេតុនៃបណ្តឹងឧទ្ធរណ៍នេះ ។

## ខ. ការឃុំខ្លួនបណ្តោះអាសន្នស្ថិតនៅជាវិធានការចាំបាច់មួយសម្រាប់ធានាឱ្យប្រាកដអំពីវត្តមានរបស់ដើមបណ្តឹងឧទ្ធរណ៍នៅក្នុងពេលសវនាការជាងដែល

១១. អង្គបុរេជំនុំជម្រះបានកំណត់ កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨ ថា ការឃុំខ្លួនបណ្តោះអាសន្ននៅមន្ទីរឃុំឃាំងរបស់ អវតក គឺជាការចាំបាច់ អនុលោមតាមវិធាន ៦៣.៣.ខ.៣ នៃវិធានផ្ទៃក្នុងដោយផ្អែកលើមូលដ្ឋានថា ដើមបណ្តឹងឧទ្ធរណ៍អាចនឹងប្រឈមនិងការផ្តន្ទាទោសដាក់ពន្ធនាគារពីប្រាំឆ្នាំដល់អស់មួយជីវិត បើសិនជាត្រូវបានរកឃើញថា មានទោស ។ ដើមបណ្តឹងឧទ្ធរណ៍តវ៉ាវិញថា ស្ថានភាពនៅក្នុងពេលនេះគឺវាខុសគ្នាព្រោះគាត់មានអាយុ៨៤ឆ្នាំហើយ នឹងមានសុខភាពមិនល្អទៀតផង ។ ប៉ុន្តែនៅក្នុងសេចក្តីសម្រេចលើកទី១លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួន អង្គបុរេជំនុំជម្រះបានពិចារណាអំពីវ័យដ៏ចាស់ជរារបស់ដើមបណ្តឹងឧទ្ធរណ៍រួចហើយ (ហើយតាមស្មាន គឺអំពីសេចក្តីកង្វល់ពីបញ្ហាសុខភាពដែលអមជាមួយនឹងវ័យជរាផង) និងព្រមទាំងបានកំណត់ថា អង្គជំនុំជម្រះបានចាត់ទុកថា ជាកាលៈទេសៈមួយនៃស្ថានទម្ងន់ គឺមិនមែនជាស្ថានសម្រាលនោះទេ នៅពេលពិចារណាអំពីហានិភ័យនៃការរត់គេចខ្លួន[22] ។ ជាងនេះទៅទៀត ការជជែកតវ៉ាដែលថា ដើមបណ្តឹងឧទ្ធរណ៍គឺជាបុគ្គលដែលមានឈ្មោះល្បីមួយរូបនោះក៏អាចចាត់ទុកថាជាស្ថានទម្ងន់ដែរ គឺមិនមែនចាត់ទុកជាស្ថានសម្រាលនោះទេ ព្រោះដោយសារគាត់មិនទំនងជាមនុស្សដែលគ្មានទំនាក់ទំនងសោះ ដើម្បីឱ្យគេជួយគាត់ក្នុងការរត់គេចខ្លួននោះទេ ។ ស្រដៀងគ្នានេះ ភាពផ្ទុយគ្នារវាង អវតក ហើយនឹងតុលាការ ICC, ICTY, និង ICTR ទាក់ទងទៅនឹងការមានស្រាប់នូវនគរបាលយុត្តិធម៌ និងដីកាបង្គាប់ឱ្យនាំខ្លួននានា គឺមិនអាចជួយអ្វីបាននោះទេ ព្រោះ អវតក គឺជាតុលាការខុសពីគេដែលមានតែមួយគត់នៅក្នុងប្រទេសកម្ពុជាដែលកាត់ទោសចំពោះបទឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរនានា ដែលមានទំហំដែលមិនធ្លាប់មានពីមុនមកដែលត្រូវដោះស្រាយអំពីការរត់គេចខ្លួន ដែលមានស្ថានទម្ងន់ផ្សារភ្ជាប់ទៅនឹងភាពជិតដឹតនៃទំនាក់ទំនងនានា និងភាពងាយស្រួលក្នុងការរត់គេចខ្លួនដែលនៅតុលាការក្រុងផ្សេងៗទៀតមិនមានដូច ។ លើសពីនេះ បញ្ហាអំពីនគរបាលយុត្តិធម៌ និងដីកាបង្គាប់ឱ្យនាំខ្លួនដែលដើមបណ្តឹឧទ្ធរណ៍បានលើកឡើង

[22] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួន។

គឺគ្រាន់តែទាក់ទងនឹងការដែលគាត់បានរត់គេចខ្លួនហើយប៉ុណ្ណោះ ដែលមិនអាចធ្វើអ្វីបានដើម្បីធានាអះអាងសារជាថ្មីចំពោះតុលាការនេះថា ការរត់គេចខ្លួនបែបនេះមិនអាចមានលទ្ធភាពធ្វើទៅរួចនោះឡើយ ។ ចាប់តាំងពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨ ដើមបណ្តឹងឧទ្ធរណ៍ពុំបានផ្តល់នូវភស្តុតាងថ្មីណាមួយដែលអាចធ្វើឲ្យអង្គបុរេជំនុំជម្រះ ជឿជាក់ ដើម្បីកែប្រែការយល់ឃើញរបស់ខ្លួនកន្លងមកនោះទេ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សនិទានភាពដែលបានលើកឡើងនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តចិរវេលា នៃការឃុំខ្លួនលើកទីមួយ គឺកំពុងនៅមានសុពលភាពនៅឡើយ ហើយគួរតែត្រូវបានតំកល់ទុកជាបានការ ដើម្បីការពារនូវស្មារតីនៃវិធាន ៦៣.៣.ខ ។

១២. ហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើអង្គបុរេជំនុំជម្រះ សម្រេចថា ការឃុំខ្លួននៅមន្ទីរឃុំឃាំងគឺកំពុងនិងបន្តត្រូវទៅតាមលក្ខខណ្ឌនានានៃការឃុំខ្លួន ទៅតាមវិធាន ៦៣.៣.ខ(៣) នៃវិធានផ្ទៃក្នុង ដូច្នេះ គឺវាបានធ្វើយុត្តិកម្មលើការបន្តចិរវេលានៃការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ ។

## គ. ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាមធ្យោបាយចាំបាច់ ដើម្បីធានាសន្តិសុខរបស់ដើមបណ្តឹង

១៣. អង្គបុរេជំនុំជម្រះ បានកំណត់កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៨ ថាការឃុំខ្លួនបណ្តោះអាសន្ននៅមន្ទីរឃុំឃាំងរបស់ អវតក គឺជាការចាំបាច់ទៅតាមវិធាន ៦៣.៣.ខ(៤) នៃវិធានផ្ទៃក្នុង ដោយមានមូលដ្ឋាននៅលើការចោទប្រកាន់អំពីភាពមានការជាប់ទាក់ទងគ្នារវាង[redacted]និង ដើមបណ្តឹងឧទ្ធរណ៍ មានន័យថា ហានិភ័យនៃអាកប្បកិរិយារំលោភ ពីសំណាក់សាធារណៈជនដែលបញ្ចេញដាក់ចំពោះអ្នកមុន ក៏អាចត្រូវបានបញ្ចេញដាក់ចំពោះអ្នកក្រោយៗដែរ[23] ។ ដើមបណ្តឹងឧទ្ធរណ៍កត់សម្គាល់ថាខ្លួនបាន "ពន្យល់ កសចស ថាគ្មានហេតុផលណា ដែលនាំឲ្យមានការព្រួយបារម្ភចំពោះសុវត្ថិភាពរបស់លោក អៀង សារី ដោយសារតែមូលដ្ឋាន ហានិភ័យដែលមានចំពោះ[redacted]នោះទេ"[24] ។ យ៉ាងនេះក្តី ក៏ដើមបណ្តឹងពុំមែនជាអ្នកត្រូវធ្វើការកំណត់យ៉ាងដូច្នោះដែរ ។ ដើមបណ្តឹងឧទ្ធរណ៍កត់សម្គាល់បន្ថែមទៀតថាវាអាចនឹងមានការផ្លាស់ប្តូរ កាលៈទេសៈមួយជាមួយ[redacted][25] ។ ការណ៍នេះបានផ្តល់ជា

---

[23] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តចិរវេលានៃការឃុំខ្លួនលើកទីមួយ, កថាខ័ណ្ឌទី ៣៣ ។

[24] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ១៩ ។

[25] *ដូចមុនដដែល*, កថាខ័ណ្ឌទី ២០ ។

00416923



ទ្រឹស្តីក្នុងការប្រែប្រួល អារម្មណ៍នៅក្នុងសង្គមកម្ពុជា ដែលជាការប៉ាន់ស្មានយ៉ាងសុទ្ធសាធ ហើយ [redacted]លបាន រំពឹងទុកមិនអាចត្រូវបានគេចាត់ទុកថាជាការផ្លាស់ប្តូរកាលៈទេសៈមួយបានទេ ដោយហេតុថាវា នៅមិនទាន់បានកើតឡើងនៅឡើយទេ ។ ដើមបណ្តឹងបានសម្តែងបន្ថែមទៀតថាវិធានការជា ជម្រើសផ្សេងៗទៀតក្នុងការរាំង ឬឃុំខ្លួន គួរតែត្រូវបានពិចារណា[26] ។ យ៉ាងនេះក៏ដោយ អង្គបុរេជំនុំជម្រះ ធ្លាប់បានសម្រេចថា "លក្ខខណ្ឌដែលស្នើឡើងដោយជនត្រូវចោទ មិនសមស្រប តាមភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះទេ"[27] ។ ចាប់តាំងពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ដើមបណ្តឹងឧទ្ធរណ៍ពុំបានផ្តល់នូវភស្តុតាងថ្មីណាមួយដែលអាចធ្វើឲ្យអង្គបុរេជំនុំជម្រះ ជឿជាក់ ដើម្បីកែប្រែការយល់ឃើញរបស់ខ្លួនកន្លងមកនោះទេ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សនិទានភាពដែលបានលើកឡើងនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលា នៃការឃុំខ្លួនលើកទីមួយ គឺកំពុងនៅមានសុពលភាពនៅឡើយ ហើយគួរតែត្រូវបានតំកល់ទុកជាបានការ ដើម្បីការពារនូវស្មារតីនៃវិធាន ៦៣.៣.ខ ។

១៤. ហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើអង្គបុរេជំនុំជម្រះ សម្រេចថា ការឃុំខ្លួននៅមន្ទីរឃុំឃាំង គឺកំពុងនិងបន្តត្រូវទៅតាមលក្ខខណ្ឌនានានៃការឃុំខ្លួន ទៅតាមវិធាន ៦៣.៣.ខ(៤) នៃវិធានផ្ទៃក្នុង ដូច្នេះ គឺវាបានធ្វើយុត្តិកម្មលើការបន្តថិរវេលានៃការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ ។

## ឃ. ការឃុំខ្លួនបណ្តោះអាសន្ននៅតែជាមធ្យោបាយចាំបាច់ ដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ

១៥. អង្គបុរេជំនុំជម្រះ បានកំណត់កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ថាការឃុំខ្លួនបណ្តោះអាសន្ននៅនៅមន្ទីរឃុំឃាំងរបស់ អវតក គឺជាការចាំបាច់ទៅតាមវិធាន ៦៣.៣.ខ(៥) នៃវិធានផ្ទៃក្នុង ដោយមានមូលដ្ឋានមួយថា ការដោះលែងដើមបណ្តឹងឧទ្ធរណ៍នឹងពិតជាបណ្តាលធ្វើឲ្យខូចដល់សណ្តាប់ធ្នាប់សាធារណៈ[28]។ ដើមបណ្តឹងឧទ្ធរណ៍ជំទាស់ថា ការឈឺចាប់របស់សាធារណៈជននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ មិនអាចយកមកធ្វើជាមូលដ្ឋានមួយដើម្បីសម្រេចអំពីការបន្ត

[26] *ដូចមុនដដែល ។*

[27] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ, កថាខ័ណ្ឌទី ៤៨ ។

[28] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ, កថាខ័ណ្ឌទី ៣៧ ។

00416924



បិរវេលានៃការឃុំខ្លួនបានទេ នៅក្រោមការយល់ច្រឡំថាការឃុំខ្លួនត្រូវបានគេយកមកប្រើប្រាស់ជាគោលបំណងក្នុងការដាក់ទណ្ឌកម្ម[29] ។ យ៉ាងនេះក៏ដោយ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តបិរវេលា នៃការឃុំខ្លួនលើកទីមួយ មិនត្រូវបានគេធ្វើឡើងជាវិធានការក្នុងការដាក់ទណ្ឌកម្មទេ ក៏ប៉ុន្តែវាជា សេចក្តីសម្រេចមួយដែលស្វែងរកនូវការរារាំងដើម្បីកុំឲ្យខូចដល់សណ្តាប់ធ្នាប់សាធារណៈ[30]។ ដើមបណ្តឹងឧទ្ធរណ៍ជំទាស់ថា "មិនមានអ្នកណាម្នាក់យកចិត្តទុកដាក់ អំពីការគំរាមកំហែងអស្ថេរភាពឲ្យបានខ្លាំងក្លាទេ"[31] ក៏ប៉ុន្តែថា ការធ្វើដូច្នោះ គឺបានប៉ុនប៉ងយកសេចក្តីវិនិច្ឆ័យរបស់ខ្លួន ដោយពុំបានចង្អុលភស្តុតាង ទៅជំនួសឲ្យសេចក្តីវិនិច្ឆ័យរបស់អង្គបុរេជំនុំជម្រះ ។ លើសពីនេះទៀត វាមិន ច្បាស់លាស់ទេថាតើសេចក្តីសម្អាងដែលថាពុំមានការខូចដល់សណ្តាប់ធ្នាប់សាធារណៈ នៅពេល មានការប្រកាសថានឹងមានការស៊ើបសួរទៅលើជនសង្ស័យចំនួនប្រាំរូបបន្ថែមទៀតនោះ នឹងមានទម្ងន់អ្វីខ្លះទៅលើឥទ្ធិពលជាសក្តានុពលទៅលើសណ្តាប់ធ្នាប់សាធារណៈ ដែលថាការដោះលែងជន ត្រូវចោទត្រូវបានគេដឹងឮយ៉ាងទូលំទូលាយ ដូចដែលដើមបណ្តឹងឧទ្ធរណ៍ និងអ្នកចូលរួមជាមួយ [redacted] អាច នឹងមានគេដឹងឮបាន ។ ចាប់តាំងពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ដើមបណ្តឹងឧទ្ធរណ៍ពុំបានផ្តល់នូវភស្តុតាងថ្មីណាមួយដែលអាចធ្វើឲ្យអង្គបុរេជំនុំជម្រះ ជឿជាក់ ដើម្បីកែប្រែការយល់ឃើញរបស់ខ្លួនកន្លងមកនោះទេ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សនិទានភាពដែលបានលើកឡើងនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តបិរវេលា នៃការឃុំខ្លួនលើកទីមួយ គឺកំពុងនៅមានសុពលភាពនៅឡើយ ហើយគួរតែត្រូវបានតំកល់ទុកជាបានការ ដើម្បីការពារនូវស្មារតីនៃវិធាន ៦៣.៣.ខ ។

១៦. ហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើអង្គបុរេជំនុំជម្រះ សម្រេចថា ការឃុំខ្លួននៅមន្ទីរឃុំឃាំង គឺកំពុងនិងបន្តត្រូវទៅតាមលក្ខខណ្ឌនានានៃការឃុំខ្លួន ទៅតាមវិធាន ៦៣.៣.ខ(៥) នៃវិធានផ្ទៃក្នុង ដូច្នេះ គឺវាបានធ្វើយុត្តិកម្មលើការបន្តបិរវេលានៃការឃុំខ្លួនដើមបណ្តឹង ។

## ខ. ជម្រើសផ្សេងៗទៅនឹងការឃុំខ្លួន មិនសមស្របតាមភាពចាំបាច់ សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នទេ

[29] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ២២ ។

[30] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តបិរវេលានៃការឃុំខ្លួនលើកទីមួយ, កថាខ័ណ្ឌទី ៣៥-៣៧ ។

[31] បណ្តឹងឧទ្ធរណ៍, កថាខ័ណ្ឌទី ២២ ។

១៧. អង្គបុរេជំនុំជម្រះ បានកំណត់កាលពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ថាការឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អវតក គឺជាការចាំបាច់ទៅតាមវិធាន ៦៣.៣ ហើយថាជម្រើសផ្សេងៗទៅនឹងការឃុំខ្លួន គឺមិនសមស្របតាមភាពចាំបាច់សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទនោះទេ[32] ។ ដូចដែលបានសម្អាងនៅខាងដើម ដោយហេតុថាភាពចាំបាច់នៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន មិនបានកាត់បន្ថយអ្វីទេ នោះជម្រើសនៅក្នុងការឃុំខ្លួនគឺនៅបន្តមានទម្ងន់ច្រើនជាងដដែល ។ ចាប់តាំងពីថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០០៩ ដើមបណ្តឹងឧទ្ធរណ៍ពុំបានផ្តល់នូវភស្តុតាងថ្មីណាមួយដែលអាចធ្វើឲ្យអង្គបុរេជំនុំជម្រះ ជឿជាក់ ដើម្បីកែប្រែការយល់ឃើញរបស់ខ្លួនកន្លងមកនោះទេ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា សនិទានភាពដែលបានលើកឡើងនៅក្នុងសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ គឺកំពុងនៅមានសុពលភាពនៅឡើយ ហើយគួរតែត្រូវបានតំកល់ទុកជាបានការ ដើម្បីការពារនូវស្មារតីនៃវិធាន ៦៣.៣.ខ ។លើសពីនេះ ដោយសារវាពុំមានការប្រែប្រួលកាលៈទេសៈណាមួយ ដែលអាចមានឥទ្ធិពលទៅលើភាពគួរទុកជាការពិតបាននៃជម្រើសផ្សេងៗទៅនឹងការឃុំខ្លួនទេនោះ សហចៅក្រមស៊ើបអង្កេត មិនបានបំពានទៅលើឆន្ទានុសិទ្ធិរបស់ខ្លួន ឬមានការខកខាននៅក្នុងការទទួលខុសត្រូវរបស់ខ្លួន ទៅតាមវិធាន ២១.១ និងវិធាន ២១.២ នៃវិធានផ្ទៃក្នុងនោះទេ ។

១៨. ហេតុដូច្នេះ សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ សម្រេចថា ការឃុំខ្លួននៅមន្ទីរឃុំឃាំងរបស់ អវតក ទៅតាមវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុង គឺកំពុងនិងបន្តត្រូវទៅតាមលក្ខខណ្ឌនានានៃការឃុំខ្លួន ដូច្នេះ វាបានធ្វើយុត្តិកម្មលើការបន្តថិរវេលានៃការឃុំខ្លួនដើមបណ្តឹងឧទ្ធរណ៍ដោយមិនគិតអំពីទម្រង់នៃការឃាត់ឃាំងជាជម្រើសផ្សេងៗទៀតទេ ។ ដូច្នេះហើយ សំណើសុំដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាទម្រង់នៃការ "ឃុំខ្លួននៅក្នុងផ្ទះ" ឬដាក់ឲ្យស្ថិតនៅក្រោមលក្ខខណ្ឌដទៃទៀត គួរតែត្រូវបានច្រានចោល ។

---

[32] សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបន្តថិរវេលានៃការឃុំខ្លួនលើកទីមួយ, កថាខ័ណ្ឌទី ៤៨ ។

## ៤. សេចក្តីសន្និដ្ឋាន

១៩. សហព្រះរាជអាជ្ញា ស្នើឲ្យ អង្គបុរេជំនុំជម្រះ បដិសេធបណ្តឹងឧទ្ធរណ៍នេះចោល ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៩ | លោកស្រី ជា លាង<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | លោក William SMITH<br>សហព្រះរាជអាជ្ញារង | Adelaide | |